ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន

## លទ្ធផលនៃមហាសន្និបាតលើកទី៦ នៃក្រុមប្រឹក្សាលើកតម្កើងហ្វ្រង់កូហ្វូនីនៅកម្ពុជា (CPFC)

នៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែមីនា ឆ្នាំ២០២៣ ក្រុមប្រឹក្សាលើកតម្កើងហ្វ្រង់កូហ្វូនីនៅកម្ពុជា (CPFC) បានរៀបចំមហាសន្និបាតលើកទី៦ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាពរបស់ឯកឧត្តម ឈិវ យីស៊ាង រដ្ឋលេខាធិការ និងជាអ្នកសម្របសម្រួលជាតិអមអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី (OIF) ដោយមានការចូលរួមរបស់លោក Edgar DOERIG តំណាងអង្គការ OIF ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិកដែលទើបតែងតាំងថ្មី និងលោក Laurent SERMET នាយក AUF ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ព្រឹត្តិការណ៍នេះក៏មានការចូលរួមផងដែររបស់តួអង្គហ្វ្រង់កូហ្វូនទាំងអស់នៅប្រទេសកម្ពុជា ដែលជាស្ថាប័នសមាជិក CPFC ស្ថានទូតនៃប្រទេសហ្វ្រង់កូហ្វូន គ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងតំណាងកងរក្សាសន្តិភាព និងដោះមីនកម្ពុជា សង្គមស៊ីវិល មជ្ឈដ្ឋានធុរកិច្ច និងសារព័ត៌មាន។

ក្រុមប្រឹក្សា CPFC បានស្តាប់លោក Edgar DOERIG ធ្វើការណែនាំខ្លួន និងបង្ហាញដោយសង្ខេបពីសកម្មភាពដែលលោកមានបំណងអនុវត្តនៅក្នុងតំណែងជាតំណាងអង្គការ OIF ប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដែលផ្តោតសំខាន់ទៅលើការលើកតម្កើងលទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍប្រកបដោយចីរភាព ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច សមភាពយេនឌ័រ និងការពង្រឹងសន្តិភាព។ លោក DOERIG នឹងព្យាយាមពង្រឹងសមត្ថភាពរបស់សង្គមស៊ីវិល។ ក្នុងនាមក្រុមប្រឹក្សា CPFC ឯកឧត្តម ឈិវ យីស៊ាង បានស្វាគមន៍យ៉ាងកក់ក្តៅ និងប្រសិទ្ធពរជ័យជូនចំពោះលោក Edgar DOERIG។

ក្រុមប្រឹក្សា CPFC បានកត់សម្គាល់នូវសុន្ទរកថារបស់លោក Laurent SERMET តំណាង AUF ដែលបានថ្លែងដោយសង្ខេបពីវឌ្ឍនភាពនៃគ្រឹះស្ថានឧត្តមសិក្សាទាំង ១៣ ដែលជាសមាជិករបស់ទីភ្នាក់ងារ AUF នៅកម្ពុជា ការបង្កើតមជ្ឈមណ្ឌលការងារហ្វ្រង់កូហ្វូននៅបាត់ដំបង ការផ្តល់ការគាំទ្រដល់សាកលវិទ្យាល័យ និងបានសង្កត់ធ្ងន់លើកិច្ចខិតខំប្រឹងប្រែងរបស់ទីភ្នាក់ងារ AUF ទាក់ទងនឹងការងាររបស់យុវជនកម្ពុជា។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

នៅក្នុងសុន្ទរកថាបើកមហាសន្និបាតក្រុមប្រឹក្សា CPFC ឯកឧត្តមរដ្ឋលេខាធិការ ឈឺវ យីស៊ាង បានបង្ហាញពីគោលនយោបាយហ្វ្រង់កូហ្វូនីរបស់កម្ពុជានៅអាស៊ី-ប៉ាស៊ីហ្វិក ដែលបានក្លាយជាតំបន់អាទិភាពនៃពិភពលោក នៅក្នុងវិស័យជាច្រើន ដូចជា សេដ្ឋកិច្ច ពាណិជ្ជកម្មអន្តរជាតិ និងលំហូរហិរញ្ញវត្ថុ។ ឯកឧត្តម ឈឺវ យីស៊ាង បានរំឭកពីជំហររបស់កម្ពុជាចំពោះសំណុំរឿងសំខាន់ៗបច្ចុប្បន្ននៃពិភពលោក និងសកម្មភាពរបស់កម្ពុជានៅលើឆាកអន្តរជាតិ។ ឯកឧត្តមរដ្ឋលេខាធិការបានផ្តោតសំខាន់ទៅលើសន្តិភាព និងសន្តិសុខ ដែលជាមូលដ្ឋានគ្រឹះនៃសណ្តាប់ធ្នាប់ពិភពលោក។

ឯកឧត្តមរដ្ឋលេខាធិការ បានសាទរចំពោះការបោះឆ្នោតជ្រើសរើសលោកជំទាវ Louise MUSHIKIWABO ជាអគ្គលេខាធិការអង្គការ OIF សម្រាប់អាណត្តិទី២ និងបានបង្ហាញនូវលទ្ធផលនៃកិច្ចប្រជុំកំពូលប្រមុខរដ្ឋ/រដ្ឋាភិបាលហ្វ្រង់កូហ្វូនី នៅកោះ Djerba ប្រទេសទុយនីស៊ី។

បន្ទាប់មក សមាជិកក្រុមប្រឹក្សា CPFC ចំនួន២២ រូប បានឡើងធ្វើបទបង្ហាញម្តងម្នាក់អំពីសកម្មភាពការងារដែលពួកគេបានធ្វើរយៈពេល ១២ ខែចុងក្រោយនេះ។ ស្ថានទូតបារាំង ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សាលាភូមិន្ទរដ្ឋបាល វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានបង្ហាញពីសកម្មភាពរបស់ខ្លួននៅក្នុងវិស័យអប់រំ។ ស្ថានទូតថៃបានបង្ហាញពីសកម្មភាពហ្វ្រង់កូហ្វូនដែលបានអនុវត្តនៅប្រទេសថៃ។ តំណាងមកពីរដ្ឋសភាជាតិ និងព្រឹទ្ធសភា បានធ្វើបទបង្ហាញអំពីកិច្ចសហប្រតិបត្តិក្នុងក្របខណ្ឌហ្វ្រង់កូហ្វូនី។ វិស័យឯកជន និងសភាពាណិជ្ជកម្មបានលើកឡើងពីបញ្ហាប្រឈមពាក់ព័ន្ធនឹងហ្វ្រង់កូហ្វូនី។ សង្គមស៊ីវិលបានបង្ហាញពីកម្មវិធីរបស់ខ្លួន តាមរយៈសំឡេងរបស់សមាគម។ សាលារាជធានីភ្នំពេញ និងសាលាខេត្តព្រះសីហនុ បានលើកឡើងពីបញ្ហាប្រឈមរបស់ខ្លួន សម្រាប់ឆ្នាំ២០២៣ និងឆ្នាំ២០២៤។ ជាចុងបញ្ចប់ មជ្ឈមណ្ឌល NPMEC បានបង្ហាញពីសកម្មភាពរបស់ខ្លួន ដើម្បីបម្រើដល់បេសកកម្មរក្សាសន្តិភាព និងការដោះមីន និងកិច្ចសហប្រតិបត្តិការដែលផ្តល់ដោយប្រទេសបារាំង។

ក្រុមប្រឹក្សា CPFC បានស្តាប់លោក ចាន់ បូនីរ៉ា ប្រធាននាយកដ្ឋានហ្វ្រង់កូហ្វូនីនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បង្ហាញដោយសង្ខេបពីសកម្មភាពរបស់នាយកដ្ឋានរយៈពេលប៉ុន្មានខែចុងក្រោយនេះ។ លោក ចាន់ បូនីរ៉ា បានចែករំលែកព័ត៌មាន ជាពិសេសទាក់ទងនឹងកិច្ចប្រជុំ RESIFAP នៅនូវែលកាលេដូនី។

ក្រុមប្រឹក្សា CPFC បានអនុម័តដោយក្តីរីករាយលើការបញ្ចូលសមាជិកថ្មីចំនួន ៤៖ សាលាខេត្តព្រះសីហនុ សមាគមយុវជន ក្រុមហ៊ុន Auskhmer និងក្រុមហ៊ុន Business Center Cambodia។ លើសពីនេះទៀត ក្រុមប្រឹក្សាបានសម្រេចថារៀបចំកិច្ចប្រជុំនាពេលខាងមុខដើម្បីពិភាក្សាពីសំណើទាក់ទងនឹងការអនុម័តការធ្វើជាប្រធានប្តូរវេននៃក្រុមប្រឹក្សា CPFC។

ក្នុងនាមជាប្រធានមហាសន្និបាត ឯកឧត្តមរដ្ឋលេខាធិការបានប្រកាសថា ហ្វ្រង់កូហ្វូនីនៅកម្ពុជាមានភាពរស់រវើក និងផ្តោតសំខាន់ទៅលើតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ឯកឧត្តមបានបន្ថែមថា

ឆ្នាំ២០២៣ គឺជាឆ្នាំនៃការបង្កើតទំនាក់ទំនងថ្មីៗ និងការធ្វើសកម្មភាពរួមនៅក្នុងតំបន់របស់យើង ក្រោមឆ័ត្ររបស់អង្គការ OIF។

ឯកឧត្តមរដ្ឋលេខាធិការ ឈីវ យីស៊ាង បានថ្លែងអំណរគុណចំពោះអ្នកចូលរួមដែលមានចំនួនច្រើន និងបានប្រកាសបិទកិច្ចប្រជុំនេះ ដោយអញ្ជើញចូលរួមពិធីជប់លៀងដែលរៀបចំឡើងនៅភោជនីយដ្ឋាន Villa 5 Contemporary Cuisine ជុំវិញប្រធានបទ "321 millions de francophones, des milliards de contenus culturels"។